ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន

# សេចក្ដីជូនព័ត៌មាន
# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ
# ពីថ្ងៃទី ១២ ដល់ ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧
# ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន

---------------------

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ក្រោមមូលបទ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្ដូរ រួមចំណែកជាមួយពិភពលោក" ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន តបតាមការអញ្ជើញរបស់ឯកឧត្តម **រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ (Rodrigo Roa Duterte)** ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន។

I. <u>កិច្ចប្រជុំកំពូល និងសកម្មភាពនានា</u>

១- <u>កិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១</u> (ថ្ងៃទី១៣ ខែវិច្ឆិកា)

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានស្នើអាស៊ាន៖ លើកកំពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់ថែមទៀត ពង្រឹងគោរពគោលការណ៍កុងសង់ស៊ុសសម្រាប់ការសម្រេចចិត្តនានា ផ្ដោតសារសំខាន់ឲ្យបានខ្លាំងដល់ការអនុវត្តសេចក្ដីសម្រេចនានាដែលអាស៊ានបានអនុម័តកន្លងមក ត្រៀមលក្ខណៈយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលអាស៊ាន ដោយឈរលើគោលការណ៍គម្លាតអភិវឌ្ឍន៍ផ្សេងៗគ្នាក្នុងចំណោមប្រទេសសមាជិកអាស៊ានលើកកំពស់និងពន្លឿនការចរចាស្ដីពីភាពជាដៃគូសេដ្ឋកិច្ចតំបន់ទូលំទូលាយ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-សហភាពអឺរ៉ុប និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា។

កិច្ចប្រជុំកំពូលបានធ្វើការពិភាក្សាប្រកបដោយលទ្ធផលលើបញ្ហាសំខាន់ៗជាច្រើនរបស់សសរស្ដម្ភទាំងបីរបស់សហគមន៍អាស៊ាន (សហគមន៍នយោបាយនិងសន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន សហគមន៍សង្គម-វប្បធម៌អាស៊ាន) ក៏ដូចជាទំនាក់ទំនងដៃគូខាងក្រៅរបស់អាស៊ាន បញ្ហាតំបន់ និងអន្តរជាតិ និងការអភិវឌ្ឍ។

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ថ្នាក់ដឹកនាំអាស៊ានបានចុះហត្ថលេខាលើអាស៊ានកុងសង់ស៊ុសស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ព្រមទាំងបានអនុម័តឯកសារចំនួន១១។

២-ជំនួបថ្នាក់ដឹកនាំអាស៊ានជាមួយក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន (ថ្ងៃទី១៣ ខែវិច្ឆិកា)

សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើឲ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ដែលឆ្លើយតបទៅនឹងតម្រូវការសហគ្រាសមីក្រូ-ធុនតូចនិងមធ្យម និងក្នុងការប្រែក្លាយអាស៊ានទៅជាតំបន់ដែលមានផលប្រយោជន៍ប្រកួតប្រជែងកំរិតខ្ពស់ និងឈរនៅជួរមុខនៅលើវិស័យសេដ្ឋកិច្ចឌីជីថល។

៣-កិច្ចប្រជុំកំពូលអាស៊ាន-អាមេរិកលើកទី៥ ដើម្បីប្រារព្ធខួបលើកទី៤០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អាមេរិក(ថ្ងៃទី១៣ ខែវិច្ឆិកា)

សម្តេចតេជោបានថ្លែងសរសើរសេចក្តីថ្លែងការណ៍នានា របស់ប្រធានាធិបតី ដូណាល់ ត្រាំ ដែលបានលើកឡើងនៅអង្គការសហប្រជាជាតិ កិច្ចប្រជុំកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក និងម្តងទៀតនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកថា "យើងគោរពឯករាជ្យ និងអធិបតេយ្យភាពនៃប្រទេសរបស់អ្នក យើងចង់ឱ្យអ្នកខ្លាំង រីកចំរើន និងមានឯករាជ្យដោយខ្លួនឯង ចាក់ឫសជ្រៅ ក្នុងតម្លៃប្រវត្តិសាស្ត្ររបស់អ្នក និងប្រឹងប្រែងដើម្បីអនាគតល្អប្រសើរនៃប្រជាជនអ្នក"។ សម្តេចតេជោបានបញ្ជាក់ថា រដ្ឋបាលអាមេរិកកន្លងទៅ បានប្រើប្រាស់សញ្ញាណលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដើម្បីជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេងទៀត។ យើងជាជនរងគ្រោះម្តងហើយម្តងទៀត ឥឡូវកំពុងបន្តក្លាយជាជនរងគ្រោះ ដោយសារតែសកម្មភាពរបស់អ្នកខាងក្រោមដែលដើរខុសពីបន្ទាត់នយោបាយរបស់ឯកឧត្តម។ ចំពោះបំណុលរបស់កម្ពុជា សម្តេចតេជោបានមានប្រសាសន៍ថា កម្ពុជាត្រូវបានទម្លាក់ដោយរដ្ឋប្រហារមួយដែលគាំទ្រដោយសហរដ្ឋអាមេរិក ហើយបានក្លាយទៅជាប្រទេសដែលជំពាក់បំណុលសហរដ្ឋអាមេរិក ហើយបំណុលនោះទៀតសោត គឺយើងខ្ញុំជាអ្នកទទួលមរតក ដូច្នេះយើងខ្ញុំត្រូវមានភារកិច្ចសង។ យើងបានស្នើសុំថាយើងខ្ញុំសង ប៉ុន្តែសុំស្នើឱ្យអាមេរិកបង្វែរបំណុលនោះមកជួយដល់កម្ពុជាវិញ។

ថ្នាក់ដឹកនាំបានឯកភាពក្នុងការពង្រឹងថែមទៀតទំនាក់ទំនងភាពជាដៃគូអាស៊ាន-សហរដ្ឋអាមេរិក ក៏ដូចជាកិច្ចសហប្រតិបត្តិការ និងការសហការ ក្នុងការដោះស្រាយការប្រឈមដែលទើបកើតមានឡើងក្នុងតំបន់ និងពិភពលោកដែលជាការព្រួយបារម្ភរួម។ ថ្នាក់ដឹកនាំបានកត់សំគាល់ពីតួនាទីដ៏សកម្មនៃទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន-សហរដ្ឋអាមេរិក។

៤-កិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី២០(ថ្ងៃទី១៣ ខែវិច្ឆិកា)

សម្តេចតេជោ បានវាយតំលៃខ្ពស់ចំពោះការអនុវត្តគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ វិថីមួយ និងការបង្កើតឡើងនូវធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងបានស្នើចិនឲ្យបន្តលើកទឹកចិត្តវិនិយោគិនចិនមកកម្ពុជា ជាពិសេសក្នុងវិស័យផលិតកម្មកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សហគ្រាសធុនតូចនិងមធ្យម ថាមពល និងទេសចរណ៍ ក៏ដូចជាការលើកទឹកចិត្តភ្ញៀវទេសចរចិនមកទស្សនាកម្ពុជា ច្រើនថែមទៀត។

ថ្នាក់ដឹកនាំបានកត់សម្គាល់ថា ទំនាក់ទំនងអាស៊ាន-ចិនបានប្រែក្លាយជាដៃគូសន្ទនាដ៏សំខាន់បំផុតមួយរបស់អាស៊ាន។ ថ្នាក់ដឹកនាំស្វាគមវឌ្ឍនភាពជាវិជ្ជមាននៃបញ្ហាសមុទ្រចិនខាងត្បូង ចាប់តាំងពីកិច្ចប្រជុំកំពូល

នៅឆ្នាំ២០១៦ និងបានកត់សម្គាល់ថា ក្របខ័ណ្ឌនៃក្រមប្រតិបត្តិ (COC) ដែលបានអនុម័តកាលពីខែសីហា ឆ្នាំ២០១៧ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ។ ថ្នាក់ដឹកនាំបានប្រកាសនូវជំហានបន្ទាប់ គឺការចាប់ផ្តើមកិច្ចចរចាជាផ្លូវការស្តីពីCOC។ ថ្នាក់ដឹកនាំឯកភាពបន្តការកសាងទំនុកចិត្តតាមរយៈកិច្ចសហប្រតិបត្តិការ ជាក់ស្តែងស្តីពីលំហសមុទ្រ និងបានអនុម័តសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំស្តីពីទស្សវត្សនៃកិច្ចការពារបរិស្ថានតំបន់ឆ្នេរ និងលំហសមុទ្រ នៅសមុទ្រចិនខាងត្បូង។

៥) <u>កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េ លើកទី១៩</u> (ថ្ងៃទី ១៣ ខែវិច្ឆិកា)

ក្នុងឋានៈកម្ពុជា ជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាជាមួយសាធារណរដ្ឋកូរ៉េ សម្តេចតេជោនាយករដ្ឋមន្ត្រី បានជម្រាបកិច្ចប្រជុំពីជំហររួមរបស់អាស៊ាន ដោយផ្តោតលើការវិវឌ្ឍជាវិជ្ជមានដែលសំរេចបានក្នុងទំនាក់ទំនងអាស៊ាន-សាធារណរដ្ឋកូរ៉េ និងបានជម្រាបកិច្ចប្រជុំថា កម្ពុជានឹងរៀបចំ ការផ្លាស់ប្តូរទស្សនកិច្ចរបស់យុវជនអាស៊ាន-សាធារណរដ្ឋកូរ៉េ ក្រោមប្រធានបទ “បណ្តុះបណ្តាលថ្នាក់ដឹកនាំយុវជន បង្កើតមេដឹកនាំនាពេលអនាគត” នៅក្នុងឆ្នាំ២០១៧ នៅខេត្តសៀមរាប ដែលនឹងមានអ្នកចូលរួម ជាង២៤០នាក់។

ស្តីពីស្ថានភាពឧបទ្វីបកូរ៉េ ជំនួសមុខឲ្យអាស៊ាន សម្តេចតេជោបានបញ្ជាក់ថា “អាស៊ាន និងសហគមន៍អន្តរជាតិ បានសំដែងការព្រួយបារម្ភជាខ្លាំង ចំពោះការសាកនុយក្លេអ៊ែរ និងមីស៊ីលបាលីស្ទីក នាពេលថ្មីៗនេះ របស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ ដូចនេះ យើងជម្រុញជាខ្លាំងដល់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ឲ្យបញ្ឈប់សកម្មភាពដែលរំលោភលើសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ជាបន្ទាន់ ដែលសកម្មភាពទាំងនេះបានបង្កភាពតានតឹងក្នុងតំបន់។ អាស៊ានអះអាងម្តងទៀតពីការគាំទ្រពេញទំហឹង ដល់ការរំលាយសព្វាវុធនុយក្លេអ៊ែរដោយសន្តិវិធីនៅឧបទ្វីបកូរ៉េ និងសង្ឃឹមទុកពីការចាប់ផ្តើមកិច្ចចរចា៦ភាគីឲ្យបានឆាប់រហ័ស ក៏ដូចជាកិច្ចសន្ទនា និងការពិគ្រោះយោបល់ស្ថាបនា នៅក្នុងវេទិកាតំបន់អាស៊ាន ដែលជាវេទិកាដ៏ល្អបំផុត សម្រាប់លើកកំពស់កិច្ចសន្ទនាបើកចំហរ ស្តីពីកិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខ នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ការព្រងើយកន្តើយរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េចំពោះច្បាប់អន្តរជាតិ ក៏ដូចជាការព្រួយបារម្ភដ៏ខ្លាំងរបស់សហគមន៍អន្តរជាតិ ពិតជាចោទជាបញ្ហាធ្ងន់ធ្ងរដល់ភាពស្មោះត្រង់របស់ប្រទេសនេះ ក្នុងកិច្ចសន្ទនាប្រកបដោយអត្ថន័យលើបញ្ហាជាក់ស្តែងដែលឧបទ្វីបកូរ៉េកំពុងតែប្រឈម។ អាស៊ានបន្ត ត្រៀមខ្លួនដើរតួនាទីសំខាន់របស់ខ្លួន ក្នុងការសម្រេចឲ្យបាននូវដំណោះស្រាយប្រកបដោយសន្តិវិធី និងរួមចំណែកដល់សន្តិភាព និងស្ថិរភាពលើឧបទ្វីបកូរ៉េ។ យើងបង្ហាញការគាំទ្រដល់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ក្នុងការធានាសន្តិភាពយូរអង្វែងនៅក្នុងតំបន់ និងធ្វើឲ្យប្រសើរឡើងទំនាក់ទំនងអន្តរកូរ៉េ” ។

កិច្ចប្រជុំកំពូលបានប្តេជ្ញាចិត្តដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទំនាក់ទំនងរវាងប្រជាជន កាត់បន្ថយគម្លាតអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យ សន្តិសុខនយោបាយ។ ថ្នាក់ដឹកនាំបានកត់សម្គាល់ថា សាធារណរដ្ឋកូរ៉េនៅតែជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតទី៥ របស់អាស៊ាន និងជាប្រភពវិនិយោគទុនបរទេសធំបំផុតទី៥ របស់អាស៊ាននៅក្នុងឆ្នាំ២០១៦។

៦) <u>កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២០</u>(ថ្ងៃទី១៣ ខែវិច្ឆិកា)

កម្ពុជាបានស្នើជប៉ុនបន្តលើកទឹកចិត្តវិនិយោគិន និងប្រជាជនជប៉ុនមកវិនិយោគ និងទស្សនកិច្ចនៅកម្ពុជាថែមទៀត។ សម្តេចតេជោបានសំដែងអំណរគុណដ៏ជ្រាលជ្រៅដល់ជប៉ុន ដែលបានគាំទ្រយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍធនធានមនុស្សនៅតំបន់អាស៊ាន ជាពិសេសនៅប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម និងបានស្នើជួយ និងគាំទ្រថែមទៀតតាមរយៈការបែងចែកអាហារូបករណ៍ និងការបណ្តុះបណ្តាលផ្សេងទៀត។

ថ្នាក់ដឹកនាំអាស៊ានជបានស្វាគមបំណងរបស់ជប៉ុនក្នុងការចូលរួមកាន់តែបរិសកម្មថែមទៀត ដើម្បីរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាពរបស់តំបន់ និងសហគមន៍អន្តរជាតិ ព្រមទាំងគាំទ្រនូវគោលនយោបាយជប៉ុននៃ "វិភាគទានបរិសកម្មចំពោះសន្តិភាព" និងបានកត់សម្គាល់ថា ជប៉ុនជាដៃគូពាណិជ្ជកម្មធំបំផុតទី៤ របស់អាស៊ាន និងជាដៃគូវិនិយោគធំបំផុតទី២ របស់អាស៊ាន ក្នុងឆ្នាំ២០១៦។

៧) <u>ជំនួបថ្នាក់ដឹកនាំអាស៊ានបូកបីជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ីបូព៌ា</u>(ថ្ងៃទី១៣ ខែវិច្ឆិកា)

ថ្នាក់ដឹកនាំបានសម្តែងនូវការគាំទ្រដល់ការរួមបញ្ចូលសំលេងពីវិស័យធុរកិច្ច ទៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ និងបានគូសបញ្ជាក់ពីភាពចាំបាច់ដើម្បីសម្របសម្រួលការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិច នៅក្នុងតំបន់ ក៏ដូចជាកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងដៃគូសន្ទនានានារបស់អាស៊ាន នៅក្នុងគោលបំណងនេះ។

៨) <u>កិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី៩</u>(ថ្ងៃទី១៣ ខែវិច្ឆិកា)

សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកឡើងពីការគំរាមលើសន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ បង្កឡើងដោយក្រុមជ្រុលនិយម និងភេរវកម្ម និងបានផ្តល់អនុសាសន៍ដល់អាស៊ាន និងអង្គការសហប្រជាជាតិ (អ.ស.ប) បន្តកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីលុបបំបាត់ការប៉ុនប៉ងអូសទាញយុវជនអាស៊ីអាគ្នេយ៍ទៅចូលរួមក្នុងក្រុមភេរវកម្ម និងការទប់ស្កាត់ ក្រុមភេរវជនមិនឲ្យបង្កើតមូលដ្ឋាននៅក្នុងតំបន់។ សម្តេចតេជោបានអះអាងថា កម្ពុជានឹងបន្តបញ្ជូនកងកំលាំងរក្សាសន្តិភាពក្រោមក្របខ័ណ្ឌអ.ស.ប ទៅចូលរួមចំណែកកសាង និងរក្សាសន្តិភាព នៅក្នុងតំបន់នានានៃពិភពលោក។

ឯកឧត្តមអគ្គលេខាធិការអ.ស.ប បានបង្ហាញនូវការកោតសរសើរចំពោះបណ្តាថ្នាក់ដឹកនាំអាស៊ាន សម្រាប់ការចូលរួមចំណែកនាពេលបច្ចុប្បន្នរបស់កងកម្លាំងថែរក្សាសន្តិភាពជាង ៤៦០០ នាក់ មកពីប្រទេសសមាជិកអាស៊ានក្នុងប្រតិបត្តិការសន្តិភាព។ ថ្នាក់ដឹកនាំបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីដោះស្រាយការគំរាមគំហែង និងបញ្ហាប្រឈមនៃភេរវកម្មពិភពលោក និងអំពើហិង្សាជ្រុលនិយម ។

៩) <u>កិច្ចប្រជុំរំលឹកខួបអាស៊ានបូកបីលើកទី២០</u> (ថ្ងៃទី ១៤ ខែវិច្ឆិកា)

សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើដល់ប្រទេសអាស៊ានបូកបីបន្តគាំទ្រដល់ផែនការការងារគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ដំណាក់កាលទី៣ និងផែនការមេស្តីពីការតភ្ជាប់អាស៊ាន២០២៥ ក៏ដូចជាផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ លើកទឹកចិត្តការវិនិយោគពីប្រទេសអាស៊ានបូកបី ជាពិសេសមកកាន់សមាជិកដែលមានការអភិវឌ្ឍយឺត។

ថ្នាក់ដឹកនាំបានចេញផ្សាយសេចក្ដីថ្លែងការណ៍ទីក្រុងម៉ានីលស្ដីពីខួបលើកទី២០ នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី និងអនុម័តសេចក្ដីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានបូកបី ស្ដីពីសន្តិសុខស្បៀង។

ថ្នាក់ដឹកនាំសម្ដែងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះសកម្មភាពបង្កហេតុ និងការគំរាមកំហែងនាពេលថ្មីៗនេះរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងស្នើដល់ប្រទេសនេះឲ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនជាបន្ទាន់នូវរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ថ្នាក់ដឹកនាំអាស៊ាន បានបញ្ជាក់ឡើងវិញពីការត្រៀមខ្លួនដើម្បីដើរតួនាទីស្ថាបនា ក្នុងការរួមចំណែកកសាងសន្តិភាព និងស្ថិរភាព នៅឧបទ្វីបកូរ៉េ។

១០) <u>កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-កាណាដា លើកទី៤០</u>(ថ្ងៃទី ១៤ ខែវិច្ឆិកា)

សម្ដេចតេជោនាយករដ្ឋមន្ត្រី បានស្វាគមន៍កម្មវិធីអាហារូបករណ៍សំខាន់ថ្មីនៃគម្រោងកម្មវិធីផ្លាស់ប្ដូរវិស័យអប់រំ ដែលមានថវិកា១០លានដុល្លារកាណាដា ដែលផ្ដល់ការបណ្ដុះបណ្ដាលដល់យុវជន អ្នកជំនាញវ័យកណ្ដាលជាពិសេសស្ត្រីពីកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។ សម្ដេចតេជោបានស្នើកាណាដាបន្តផ្ដល់ជំនួយបច្ចេកទេសដល់អាស៊ាន ជាពិសេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដើម្បីលើកកំពស់ការអភិវឌ្ឍគម្រោងនវានុវត្តន៍ និងកំណើនសេដ្ឋកិច្ច ព្រមទាំងពិចារណាផ្ដល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។

ថ្នាក់ដឹកនាំបានណែនាំដល់មន្ត្រីសេដ្ឋកិច្ច ចាប់ផ្ដើមកិច្ចពិភាក្សា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា ដ៏មានសក្ដានុពលមួយ ហើយនឹងតាំងចិត្តដោះស្រាយភាពក្រីក្រ និងវិសមភាព ដើម្បីបំពេញគំលាតអភិវឌ្ឍន៍នៅតំបន់អាស៊ាន។ ថ្នាក់ដឹកនាំក៏បានណែនាំមន្ត្រីពាក់ព័ន្ធនានា បង្កើនល្បឿនការអនុវត្តកម្មវិធី និងគោលដៅ ដែលបានកំណត់ក្នុងផែនការសកម្មភាព ដើម្បីអនុវត្តសេចក្ដីប្រកាសរួមស្ដីពីភាពជាដៃគូរឹងមាំអាស៊ាន-កាណាដា (២០១៦-២០២០) និងយន្តការកិច្ចសហប្រតិបត្តិការអាស៊ាន-កាណាដា ដែលមានស្រាប់ផ្សេង ទៀត។

១១) <u>កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍លើកទី៤០ ឆ្នាំ នៃទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប</u>
(ថ្ងៃទី ១៤ ខែវិច្ឆិកា)

កម្ពុជាបានសម្ដែងក្ដីសង្ឃឹមសម្រាប់ជំនួយរបស់សហភាពអឺរ៉ុប ដល់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន និងស្នើសហភាពអឺរ៉ុបបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ ដោយផ្ដល់អាហារូបករណ៍ដល់ប្រទេសសមាជិកអាស៊ាន ជាពិសេសប្រទេសសមាជិកអាស៊ាន ដែលមានការអភិវឌ្ឍតិចតួច។

ថ្នាក់ដឹកនាំបានអះអាងឡើងវិញពីសារៈសំខាន់នៃការពង្រឹងការតភ្ជាប់ជាយុទ្ធសាស្ត្រនិងភាពជាដៃគូសេដ្ឋកិច្ចរវាងសហភាពអឺរ៉ុប និងអាស៊ាន ជាមួយនឹងគោលបំណងបង្កើនពាណិជ្ជកម្ម និងវិនិយោគ រវាងតំបន់ទាំងពីរ និងអះអាងជាថ្មីពីការតាំងចិត្តសម្រេចនូវកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវអាកាសគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងសហភាពអឺរ៉ុប ដ៏មានមហិច្ឆតា និងសំលឹងឆ្ពោះទៅមុខ ព្រមទាំងបង្កើនការងារឆ្ពោះទៅបន្តកិច្ចចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-សហភាពអឺរ៉ុប។

១២)<u>កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១២</u>(ថ្ងៃទី ១៤ ខែវិច្ឆិកា)

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានផ្លាស់ប្ដូរទស្សនៈស្ដីពីឧបទ្វីបកូរ៉េ សមុទ្រចិនខាងត្បូង និងភេរវកម្ម។

ថ្នាក់ដឹកនាំថ្កោលទោសការអភិវឌ្ឍអាវុធប្រល័យលោករបស់សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ រួមមានអាវុធគីមី និងនុយក្លេអ៊ែរ បច្ចេកវិទ្យាមីស៊ីលបាលីស្ទិក ដែលផ្ទុយទៅនឹងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ថ្នាក់ដឹកនាំបានជំរុញយ៉ាងខ្លាំងឲ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េឲ្យគោរព និងអនុវត្តជាបន្ទាន់រាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងបានគូសបញ្ជាក់ថា ប្រទេសចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាបានប្តេជ្ញាអនុវត្តឲ្យបានពេញលេញ និងល្អិតល្អន់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងបានលើកទឹកចិត្តដល់រដ្ឋនានាឲ្យប្រកាន់យកវិធានការនេះ។ កិច្ចប្រជុំកំពូលបានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាមនុស្សធម៌របស់សហគមន៍អន្តរជាតិ រួមទាំងបញ្ហាចាប់ជំរិតផងដែរ។

កិច្ចប្រជុំកំពូល បានអនុម័តសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការលុបបំបាត់ភាពក្រីក្រ សេចក្តីប្រកាសថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាស្តីពីអាវុធគីមី សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ស្តីពីការប្រយុទ្ធប្រឆាំងនឹងការប្រឈមនៃមនោគមវិជ្ជាភេរវកម្ម ព្រមទាំងសកម្មភាពនិងការឃោសនាភេរវកម្ម សេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ស្តីពីការប្រឆាំងការលាងលុយ និងការប្រឆាំងការ ផ្តល់ហិរញ្ញប្បទានភេរវកម្ម។

១៣) <u>កិច្ចប្រជុំកំពូលស្តីពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់</u> (ថ្ងៃទី១៤ ខែវិច្ឆិកា)

បន្ទាប់ពីបានកត់សម្គាល់ថា កិច្ចប្រជុំកំពូលនេះ គឺជាកិច្ចប្រជុំលើកទីមួយ ក្នុងរយៈពេលប្រាំឆ្នាំ បន្ទាប់ពីចាប់ផ្តើមការចរចារ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ក្នុងទីក្រុងភ្នំពេញ និងឃើញថា ការចរចារមានភាពរីកចម្រើនទៅមុខ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តឲ្យមានការប្តេជ្ញាចិត្តខាងផ្នែកនយោបាយ ក្នុងការជំរុញកិច្ចចរចារទៅមុខ ដើម្បីធានាឲ្យបានថា កិច្ចព្រមព្រៀងនេះអាចនឹងត្រូវបានចុះហត្ថលេខាឆាប់ៗ យោងតាមអណត្តិថ្មី នៅចុងឆ្នាំ២០១៨។

ថ្នាក់ដឹកនាំបានណែនាំដល់រដ្ឋមន្ត្រី និងអ្នកចរចា ឲ្យពង្រឹងកិច្ចប្រឹងប្រែងរបស់ខ្លួន នៅឆ្នាំ២០១៨ ដើម្បីបញ្ចប់ការចរចាភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងតាំងចិត្តជានាឲ្យមានការគាំទ្រចាំបាច់នានាដើម្បីសម្រេចបានលទ្ធផលនេះ។

១៤) <u>កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី១៥</u> (ថ្ងៃទី ១៤ ខែវិច្ឆិកា)

សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តឥណ្ឌា ឲ្យដើរតួនាទីគន្លឹះ ក្នុងការធ្វើឲ្យសម្រេចបាននូវផ្លូវហាយវ៉េ ត្រីភាគីឥណ្ឌា-មីយ៉ាន់ម៉ារ-ថៃ និងបន្តដល់ឡាវ និងកម្ពុជា និងការកសាងផ្លូវហាយវ៉េថ្មីតភ្ជាប់ឥណ្ឌា-មីយ៉ាន់ម៉ារ-ឡាវ-វៀតណាម-កម្ពុជា។

ថ្នាក់ដឹកនាំបានលើកទឹកចិត្តការសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវអាកាសអាស៊ាន- ឥណ្ឌា និងកិច្ចព្រមព្រៀងដឹកជញ្ជូនតាមសមុទ្រអាស៊ាន- ឥណ្ឌា។ ថ្នាក់ដឹកនាំរំពឹងឆ្ពោះទៅការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន- ឥណ្ឌា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥- ២៦ ខែមករា ឆ្នាំ២០១៨ នៅទីក្រុងញូវដែលីក្រោមមូលបទ "តំលៃរួម វិបុលភាពរួម"។

១៥)**កិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន លើកទី៩**(ថ្ងៃទី ១៤ ខែវិច្ឆិកា)

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបានស្វាគមន៍កិច្ចប្រឹងប្រែងស្អិតស្អេរបស់ជប៉ុន ក្នុងការបង្កើតឡើងនូវផែនការហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពនៅកម្ពុជា ជាពិសេស ការធ្វើឲ្យប្រសើរឡើងផ្លូវជាតិលេខ៥ (បាត់ដំបង-ស៊ីសុផុន) និងផែនការអភិវឌ្ឍចំណតកុងទើណ័រថ្មី នៅក្រុងព្រះសីហនុ។ សម្តេចតេជោបានបញ្ជាក់ពីក្តីរំពឹងដល់ ការបញ្ចប់ការសិក្សាពីផែនការអភិវឌ្ឍន៍ផ្លូវហាយវេភ្នំពេញ-បាវិត ផែនការពង្រីកប្រព័ន្ធចែកចាយ និងផ្ទេរក៏ដូចជា ផែនការពង្រីកការចែកចាយច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង។ សម្តេចតេជោបានអំពាវនាវដល់ជប៉ុនមកធ្វើការ វិនិយោគបន្ថែមទៀត ដល់អនុតំបន់មេគង្គ។

កិច្ចប្រជុំកំពូលបានអនុម័តសេចក្តីប្រកាសរួមៈ ស្វាគមការបន្តអនុវត្តភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព, បញ្ជាក់ឡើងវិញពីសារៈសំខាន់នៃការពង្រឹងការតភ្ជាប់ផ្នែកទន់ (soft connectivity), លើកសរសើរការវិវត្តគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ធនធានមនុស្សឧស្សាហកម្ម និងស្វាគមន៍បំណងរួមគ្នារបស់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងជប៉ុន ក្នុងការបង្កើតយន្តការធានារ៉ាប់រងលើហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាគំនិតផ្តួចផ្តើមរបស់កម្ពុជា ឡាវ មីយ៉ាន់ម៉ា ដោយមានការផ្តល់ហិរញ្ញវត្ថុគ្រាដំបូងពីជប៉ុន។

១៦)**សកម្មភាពនានា**

នៅក្នុងក្របខ័ណ្ឌកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ពិសេសដើម្បីអបអរសាទរខួបលើកទី៥០ឆ្នាំ នៃការបង្កើតអាស៊ានពិសារអាហារពេលព្រឹកការងាររវាងនាយករដ្ឋមន្ត្រីទាំងបី កម្ពុជា ឡាវ និងវៀតណាម និងពិសារអាហារថ្ងៃត្រង់រៀបចំដោយប្រធានាធិបតី រ៉ូឌ្រីហ្គោឌូតឺតេ ជាកិត្តិយសដល់ប្រមុខរដ្ឋ/រដ្ឋាភិបាល និងភ្ញៀវរបស់ប្រធានកិច្ចប្រជុំ ផងដែរ។

II-**កិច្ចប្រជុំទ្វេភាគី**

បន្ថែមពីនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក៏បានជួបពិភាក្សាទ្វេភាគីផងដែរ ជាមួយឯកឧត្តម លី ខឺឈាង (Li Keqiang) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តមឌីមីទ្រី ម៉េដវ៉េដេវ (Dmitry Medvedev) នាយករដ្ឋមន្ត្រីនៃសហព័ន្ធរុស្ស៊ី និង ឯកឧត្តមអាន់តូញ៉ូ ហ្គុយតេរេស (Antonio Guterres) អគ្គលេខាធិការអង្គការសហប្រជាជាតិ។

III-**ដំណើរទស្សនកិច្ចទៅទីក្រុងក្លាក ខេត្តប៉ាប៉ាងហ្គា**(ថ្ងៃទី ១១ ខែវិច្ឆិកា)

នៅមុនពេលកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ សម្តេចតេជោ ក៏បានអញ្ជើញបំពេញទស្សនកិច្ចនៅទីក្រុងក្លាក ខេត្តប៉ាប៉ាងហ្គា ប្រទេសហ្វីលីពីន នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមការអញ្ជើញរបស់លោកជំទាវ គ្លោរីយ៉ា ម៉ាកាប៉ាហ្គាល អារ៉ូយ៉ូ (Gloria Macapagal-Arroyo) អតីតប្រធានាធិបតីហ្វីលីពីន និងជាសមាជិកសភាមណ្ឌល ប៉ាំប៉ាងហ្គាទី២។ សម្តេចតេជោ បានអញ្ជើញទៅទស្សនាតំបន់កំពង់ផែរួចពន្ធ ក្លាក ដើម្បីពិនិត្យមើលរបៀបគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធរបស់តំបន់នេះ និងអញ្ជើញពិសារអាហារពេលល្ងាចរៀបចំដោយលោកជំទាវ គ្លោរីយ៉ា ម៉ាកាប៉ាហ្គាល អារ៉ូយ៉ូ ផងដែរ។

ភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៧